UNITED NATIONS
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE AUX DROITS DE L'HOMME AU CAMBODGE

# អង្គការសហប្រជាជាតិ
# ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

*កំណត់ព័ត៌មាន*

## *ការផ្តល់សច្ចាប័ននៃពិធីសារបន្ថែមរបស់ប្រទេសកម្ពុជាលើអនុសញ្ញាប្រឆាំងទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (OPCAT)*

ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ត្រូវបានអនុម័តដោយមហាសន្និបាតអ.ស.ប នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ហើយបានចូលជាធរមានក្នុងច្បាប់អន្តរជាតិ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។ OPCATផ្តល់យន្តការបង្ការបន្ថែម ដើម្បីធានាថា រដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៨៤ប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប បំពេញបាននូវការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីហាមប្រាមការធ្វើទារុណកម្មតាមគ្រប់រូបភាព។ យន្តការទាំងនេះ មានស្ថាប័នបន្ថែមស្របគ្នាចំនួនពីរ មួយជាស្ថាប័នជាតិ ហើយមួយទៀតជាស្ថាប័នអន្តរជាតិ :

- នៅថ្នាក់អន្តរជាតិ មានគណៈកម្មាធិការមួយ ដែលមានសមាសភាពអ្នកជំនាញការអន្តរជាតិ ចំនួនដប់រូប ដែលគេហៅថា**អនុគណៈកម្មាធិការបង្ការ** ដែលនឹងធ្វើទស្សនកិច្ចនៅតាមមន្ទីរឃុំឃាំងនានាលើទឹកដីនៃរដ្ឋភាគី ដើម្បីបញ្ជាក់ថា ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្សេងទៀតមិនត្រូវបានអនុញ្ញាត។

- នៅថ្នាក់ជាតិ រដ្ឋភាគីនីមួយៗត្រូវបង្កើត **យន្តការជាតិមួយឯករាជ្យ ដើម្បីបង្ការការធ្វើទារុណកម្ម** ដែលស្របគ្នាជាមួយ**អនុគណៈកម្មាធិការបង្ការ**។ **យន្តការជាតិ**នេះក៏នឹងត្រូវធ្វើទស្សនកិច្ចនៅតាមមន្ទីរឃុំឃាំងនានា ដើម្បីបញ្ជាក់ថាការធ្វើទារុណកម្ម និងការអនុវត្តន៍ស្រដៀងគ្នានេះ មិនត្រូវបានអនុញ្ញាតឡើយ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីហាមប្រាម និងបង្ការការធ្វើទារុណកម្ម។

10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342; Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

កម្ពុជាបានក្លាយជាភាគីមួយនៃអនុសញ្ញាប្រឆាំងទារុណកម្ម នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញធានាការពារអនុសញ្ញានេះ ថាជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រា៣៨ ហាមប្រាមជាពិសេស ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្សេងទៀត និងប្រកាសថា ចំលើយសារភាពដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវយកជាភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពបានឡើយ។

ច្បាប់មួយដែលបញ្ចូលពិធីសារបន្ថែមនេះទៅក្នុងច្បាប់ជាតិ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧។ កម្ពុជាបានបំពេញសំណុំបែបបទសំរាប់ការផ្តល់សច្ចាប័ន នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ ហើយនឹងក្លាយជារដ្ឋភាគីមួយផ្លូវការនៃពិធីសារបន្ថែមនេះ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៧។ ពិធីសារនេះ ក៏នឹងត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ មាត្រា៣១ ផងដែរ។

ការទទួលយកពិធីសារបន្ថែមនេះរបស់កម្ពុជា តម្រូវឱ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងមួយចំនួន ដើម្បីអនុវត្តបទបញ្ញត្តិនៃពិធីសារបន្ថែមនេះ។ ជំហានទីមួយ គឺត្រូវបង្កើតយន្តការជាតិមួយ ដើម្បីបង្ការទារុណកម្មនៅថ្នាក់ជាតិ។ អនុលោមតាមពិធីសារនេះ យន្តការនេះត្រូវតែប្រព្រឹត្តទៅដោយឯករាជ្យ ហើយត្រូវតែស្របតាម *គោលការណ៍ក្រុងប៉ារីសស្តីពីឋានៈនៃស្ថាប័នជាតិសិទ្ធិមនុស្ស* ។ លើសពីនេះទៅទៀត បុគ្គលិកស្ថាប័ននេះ ត្រូវមានសមត្ថភាពវិជ្ជាជីវៈ និងឯករាជ្យពីការត្រួតត្រាខាងនយោបាយ និងត្រូវមានតុល្យភាពនៃភេទ ក៏ដូចជាតំណាងក្រុមជាតិពន្ធុ និងក្រុមជនភាគតិច។ ពិធីសារនេះចែងពីសិទ្ធិ និងការទទួលខុសត្រូវជាក់លាក់មួយចំនួន ដែលយន្តការនេះត្រូវមានដើម្បីបំពេញអាណត្តិរបស់ខ្លួន។ តាមលក្ខខណ្ឌនៃពិធីសារ យន្តការនេះត្រូវតែបង្កើតឡើងនៅថ្ងៃ ឬមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨។

អត្ថបទទាំងស្រុងនៃពិធីសារបន្ថែមនេះ ត្រូវបានដាក់ភ្ជាប់ជាមួយកំណត់ព័ត៌មាននេះ។

*ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧*

10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org

# ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

បានអនុម័តកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ នាសម័យប្រជុំលើកទី៥៧ នៃមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចចិត្តលេខ A/RES/៥៧/១៩៩។

ពិធីសារនេះបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងចូលជាសមាជិក ចាប់ពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៣ (គឺជាកាលបរិច្ឆេទដែលអត្ថបទដើមត្រូវបានបង្កើតឡើង) នៅទីស្នាក់ការអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងញូវយ៉ក។

## បុព្វកថា

***រដ្ឋភាគីនៃពិធីសារនេះ***

*អះអាងជាថ្មីថា* ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវបានហាមឃាត់ និងចាត់ទុកជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។

*ជឿជាក់ថា* ត្រូវចាត់វិធានការចាំបាច់ថែមទៀត ដើម្បីសំរេចគោលបំណងនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ពីនេះតទៅហៅត្រឹមថា អនុសញ្ញា ) និង ដើម្បីពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពឱ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

*រំលឹកឡើងវិញថា* មាត្រា២ និងមាត្រា១៦ នៃអនុសញ្ញាតម្រូវឱ្យរដ្ឋភាគីនីមួយៗ ចាត់វិធានការដ៏មានប្រសិទ្ធិភាពដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅលើទឹកដីណាមួយក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

*ទទួលស្គាល់ថា* រដ្ឋទាំងឡាយមានការទទួលខុសត្រូវចម្បងក្នុងការអនុវត្តន៍មាត្រាទាំងនេះ ដែលត្រូវពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន និងការគោរពឱ្យបានពេញលេញនូវសិទ្ធិមនុស្ស គឺជាការទទួលខុសត្រូវរួមមួយ ដែលមនុស្សគ្រប់រូបត្រូវរួមគ្នាអនុវត្ត ហើយស្ថាប័នអន្តរជាតិនានាដែលមានភារកិច្ចប្រតិបត្តិ ត្រូវជួយបំពេញបន្ថែម និងពង្រឹងវិធានការជាតិ។

*រំលឹកឡើងវិញថា* ការបង្ការប្រកបដោយប្រសិទ្ធិភាពប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ទាមទារការអប់រំ និងសមាយោគនៃវិធានការផ្សេងៗ ដូចជាវិធានការផ្លូវច្បាប់ រដ្ឋបាល តុលាការ និងវិធានការដទៃទៀត។

*រំលឹកឡើងវិញផងដែរថា* សន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្សបានប្រកាសជាឧឡារិកថា ការខិតខំប្រឹងលុបបំបាត់ការធ្វើទារុណកម្ម គួរផ្តោតការយកចិត្តទុកដាក់ជាសំខាន់ និងជាដំបូងគេបង្អស់លើការបង្ការ ហើយអំពាវនាវឱ្យមានការអនុម័តពិធីសារលើអនុសញ្ញានេះ ដែលមានគោលបំណងបង្កើតប្រព័ន្ធបង្ការ តាមរយៈការចូលពិនិត្យកន្លែងឃុំឃាំងនានា។

*ជឿជាក់ថា*ការការពារជនទាំងឡាយដែលត្រូវបានដកហូតសិទ្ធិសេរីភាពឱ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប អាចត្រូវពង្រឹងដោយវិធានការក្រៅផ្លូវតុលាការដែលមានចរិតជាការបង្ការ ដោយផ្អែកលើការចូលពិនិត្យជាទៀងទាត់នៅកន្លែងឃុំឃាំងនានា ដោយមានការព្រមព្រៀងដូចតទៅ :

## ផ្នែកទី ១
## គោលការណ៍ទូទៅ

### មាត្រា ១

ពិធីសារនេះមានគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យជាទៀតទាត់មួយដោយស្ថាប័នជាតិ និងអន្តរជាតិនានាដែលឯករាជ្យ នៅកន្លែងឃុំឃាំងជនទាំងឡាយដែលត្រូវបានដកហូតសេរីភាព ដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

### មាត្រា ២

១. អនុគណៈកម្មាធិការបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៃគណៈកម្មាធិការប្រឆាំងទារុណកម្ម (ពីនេះតទៅហៅត្រឹមថា អនុគណៈកម្មាធិការបង្ការ) ត្រូវបានបង្កើតឡើង និងត្រូវអនុវត្តមុខងាររបស់ខ្លួន ដូចមានចែងនៅក្នុងពិធីសារនេះ។

២. អនុគណៈកម្មាធិការបង្ការត្រូវបំពេញការងាររបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃធម្មនុញ្ញសហ

ប្រជាជាតិ ហើយត្រូវអនុវត្តស្របតាមគោលបំណង និងគោលការណ៍ផ្សេងៗនៃធម្មនុញ្ញនេះ ក៏ដូចជាលិខិតបទដ្ឋាននានារបស់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តលើជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។

៣. ដូចគ្នានេះដែរ អនុគណៈកម្មាធិការបង្ការត្រូវអនុវត្តតាមគោលការណ៍រក្សាការសំងាត់ ភាពឥតលំអៀង ភាពមិនប្រកាន់និន្នាការ សកលភាព និងគោលការណ៍សត្យានុម័ត ។

៤. អនុគណៈកម្មាធិការបង្ការ និងរដ្ឋភាគីទាំងអស់ ត្រូវសហការគ្នាអនុវត្តពិធីសារនេះ ។

## មាត្រា ៣

រដ្ឋភាគីនីមួយៗ ត្រូវបង្កើត ចាត់តាំង ឬរក្សាឱ្យមាននៅថ្នាក់ជាតិ នូវស្ថាប័នត្រួតពិនិត្យមួយ ឬច្រើន ដើម្បីបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ពីនេះតទៅហៅត្រឹមថា យន្តការបង្ការថ្នាក់ជាតិ ) ។

## មាត្រា ៤

១. អនុលោមតាមពិធីសារនេះ រដ្ឋភាគីនីមួយៗត្រូវអនុញ្ញាតឱ្យយន្តការត្រួតពិនិត្យនានា ដូចមានចែងក្នុងមាត្រា២ និងមាត្រា៣ ទៅមើលកន្លែងឃុំឃាំងណាមួយស្ថិតក្រោមដែនសមត្ថកិច្ច និងការគ្រប់គ្រងរបស់ខ្លួន ដែលជនទាំងឡាយត្រូវបាន ឬអាចត្រូវបានដកហូតសេរីភាព ទោះជាដោយតាមបញ្ជារបស់អាជ្ញាធរសាធារណៈ ឬតាមការផ្តួចផ្តើម ឬការយល់ព្រម ឬការស្រុះស្រួលគ្នាក៏ដោយ (ពីនេះតទៅហៅត្រឹមថាកន្លែងឃុំឃាំង ) ។ ប្រសិនជាចាំបាច់ ការត្រួតពិនិត្យទាំងនេះ ត្រូវមានគោលដៅដើម្បីពង្រឹងការការពារជនទាំងឡាយពីអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

២. សំរាប់គោលបំណងនៃពិធីសារនេះ ការដកហូតសេរីភាព មានន័យថារាល់ទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ឬការដាក់ជនណាម្នាក់នៅក្នុងកន្លែងឃុំឃាំងឯកជន ឬសាធារណៈដែលគេមិនអនុញ្ញាតឱ្យជននោះចាកចេញតាមចិត្ត ដោយធ្វើតាមបញ្ជារបស់អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរដទៃទៀត ។

## ផ្នែកទី ២
## អនុគណៈកម្មាធិការបង្ការ

## មាត្រា ៥

១. អនុគណៈកម្មាធិការបង្ការនេះ ត្រូវមានសមាជិក១០រូប។ បន្ទាប់ពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី៥០នៃពិធីសារនេះ ចំនួនសមាជិកអនុគណៈកម្មាធិការបង្ការត្រូវកើនឡើងដល់ ២៥រូប។

២. សមាជិកនៃអនុគណៈកម្មាធិការបង្ការ ត្រូវបានជ្រើសរើស ពីក្នុងចំណោមបុគ្គល ដែលមានអាកប្បកិរិយាសីលធម៌ខ្ពស់ មានបទពិសោធន៍ខាងវិជ្ជាជីវៈក្នុងវិស័យគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ជាពិសេសក្នុងការគ្រប់គ្រងតាមច្បាប់ព្រហ្មទណ្ឌ ពន្ធនាគារ ឬនគរបាល ឬក្នុងវិស័យផ្សេងទៀតពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន។

៣. ក្នុងសមាសភាពនៃអនុគណៈកម្មាធិការបង្ការ គេត្រូវធ្វើការពិចារណាអោយបានត្រឹមត្រូវ ដោយផ្អែកលើការបែងចែកប្រកបដោយសមភាពតាមភូមិសាស្ត្រ និងតាមភាពជាអ្នកតំណាងមកពីទំរង់ផ្សេងៗគ្នានៃអារ្យធម៌ និងតាមប្រព័ន្ធច្បាប់នៃរដ្ឋជាភាគីនានា។

៤. នៅក្នុងសមាសភាពនេះ គេក៏ត្រូវពិចារណាផងដែរអំពីតុល្យភាពនៃភាពជាតំណាងខាងយេនឌ័រ ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍សមភាព និងការមិនរើសអើង។

៥. អនុគណៈកម្មាធិការបង្ការនេះ មិនអាចមានសមាជិកពីររូប ជាជនជាតិនៃរដ្ឋតែមួយឡើយ។

៦. សមាជិកអនុគណៈកម្មាធិការបង្ការត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ត្រូវប្រកាន់ភាពឯករាជ្យ និងមិនលំអៀង ហើយត្រូវបំរើការជូនអនុគណៈកម្មាធិការបង្ការឱ្យមានប្រសិទ្ធិភាព។

## មាត្រា ៦

១. រដ្ឋភាគីនីមួយៗអាចបញ្ជូនឈ្មោះបេក្ខជន ស្របតាមកថាខ័ណ្ឌទី២ នៃមាត្រានេះ មិនអោយលើសពី ២រូប ដែលមានគុណវុឌ្ឍិ និងបំពេញតាមការទាមទារទាំងឡាយដែលមានចែងក្នុងមាត្រា៥ ហើយត្រូវផ្តល់ព័តិមានលំអិតស្តីពីគុណវុឌ្ឍិនៃបេក្ខជនទាំងនោះផង។

២. បេក្ខជនដែលទទួលការតែងតាំងត្រូវមានសញ្ជាតិរបស់រដ្ឋភាគីនៃពិធីសារនេះ

(ក) យ៉ាងហោចណាស់មានបេក្ខជន១រូប ត្រូវមានសញ្ជាតិរបស់រដ្ឋភាគីដែលតែងតាំង។

(ខ) រដ្ឋភាគីមិនអាចតែងតាំងបេក្ខជននៃជាតិខ្លួនលើសពី ២រូបបានឡើយ។

(គ) មុនពេលដែលរដ្ឋភាគីមួយតែងតាំងបេក្ខជនជាជនជាតិនៃរដ្ឋភាគីមួយទៀត រដ្ឋនេះត្រូវស្វែងរក និងទទួលការយល់ព្រមពីរដ្ឋភាគីនោះសិន។

៣. យ៉ាងហោចណាស់ ៥ខែ មុនកាលបរិច្ឆេទនៃការប្រជុំរបស់រដ្ឋភាគីទាំងឡាយ បើការបោះ

ឆ្នោតនឹងត្រូវរៀបចំធ្វើនៅក្នុងរយៈពេលនោះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើលិខិតអញ្ជើញរដ្ឋភាគីទាំងអស់ឱ្យបញ្ជូនឈ្មោះបេក្ខជនរបស់ខ្លួនមកក្នុងរយៈពេល ៣ខែ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនដែលទទួលការតែងតាំងទាំងនោះតាមលំដាប់អក្ខរក្រម ដោយបញ្ជាក់ពីឈ្មោះរដ្ឋភាគីដែលបានបញ្ជូនឈ្មោះបេក្ខជនទាំងនោះមកផង។

## មាត្រា ៧

១. សមាជិកអនុគណៈកម្មាធិការបង្ការត្រូវបានបោះឆ្នោតជ្រើសរើសតាមរបៀបខាងក្រោមនេះ :

(ក) ការពិចារណាជាបឋមត្រូវផ្តល់ជូនចំពោះការបំពេញបានតាមលក្ខណៈវិនិច្ឆ័យ និងការទាមទារដូចមានចែងក្នុងមាត្រា៥ នៃពិធីសារបន្ថែមនេះ។។

(ខ) ការបោះឆ្នោតលើកដំបូង ត្រូវធ្វើឡើងមិនឱ្យហួសពីរយៈពេល ៦ខែ ក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះទេ។

(គ) រដ្ឋភាគីទាំងឡាយត្រូវបោះឆ្នោតជ្រើសរើសសមាជិកអនុគណៈកម្មាធិការបង្ការ តាមរយៈការបោះឆ្នោតជាសម្ងាត់។

(ឃ) ការបោះឆ្នោតជ្រើសរើសសមាជិកអនុគណៈកម្មាធិការបង្ការ ត្រូវធ្វើក្នុងសម័យប្រជុំនៃរដ្ឋភាគីរយៈពេល ២ឆ្នាំម្តង តាមការកោះអញ្ជើញរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ កូរ៉ុមសម្រាប់កិច្ចប្រជុំបែបនេះគឺ ២ភាគ៣នៃរដ្ឋភាគីទាំងអស់ ។ បេក្ខជនដែលជាប់ជាសមាជិកនៃអនុគណៈកម្មាធិការបង្ការ ត្រូវតែជាបេក្ខជនដែលទទួលបានសន្លឹកឆ្នោតច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត។

២- ប្រសិនបើក្នុងកិច្ចដំណើរការបោះឆ្នោតនេះ បេក្ខជន ២រូប មានសញ្ជាតិនៃរដ្ឋភាគីតែមួយមានសិទ្ធិធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ បេក្ខជនម្នាក់ដែលទទួលបានសំលេងច្រើនជាងត្រូវធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ។ ប្រសិនបើបេក្ខជនទាំង ២រូបនេះ ទទួលបានសំលេងស្មើគ្នា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះ :

(ក) ប្រសិនបើមានតែបេក្ខជនម្នាក់ត្រូវបានតែងតាំងដោយរដ្ឋភាគីដែលបេក្ខជននោះជាជនជាតិនៃរដ្ឋនោះ បេក្ខជននោះត្រូវធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ។

(ខ) ប្រសិនបើបេក្ខជនទាំង ២រូប ត្រូវបានតែងតាំងដោយរដ្ឋភាគី ដែលបេក្ខជនទាំងនោះជាជនជាតិនៃរដ្ឋនោះ ការបោះឆ្នោតដាច់ដោយឡែក និងជាសំងាត់មួយ ត្រូវរៀបចំធ្វើឡើង ដើម្បីកំណត់ថាតើ

បេក្ខជនណាត្រូវធ្វើជាសមាជិក។

(គ) ប្រសិនជាគ្មានបេក្ខជនណាម្នាក់ត្រូវបានតែងតាំងដោយរដ្ឋភាគី ដែលបេក្ខជននោះជាជនជាតិនៃរដ្ឋនោះ ការបោះឆ្នោតដាច់ដោយឡែក និងជាសំងាត់ ត្រូវរៀបចំធ្វើឡើង ដើម្បីកំណត់ថាតើបេក្ខជនណាត្រូវធ្វើជាសមាជិក។

**មាត្រា ៨**

ប្រសិនបើសមាជិកអនុគណៈកម្មាធិការបង្ការណាម្នាក់ទទួលមរណភាពឬសុំលាឈប់ពីមុខតំណែង ឬដោយបុព្វហេតុផ្សេង ដែលមិនអាចបំពេញមុខងារឱ្យអនុគណៈកម្មាធិការបង្ការនោះបាន រដ្ឋភាគីត្រូវតែងតាំងសមាជិកមួយរូបទៀត ដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងបំពេញតាមសេចក្តីតម្រូវដូចមានចែងក្នុងមាត្រា៥ ដោយគិតគូពីសេចក្តីត្រូវការឱ្យមានតុល្យភាពត្រឹមត្រូវ ក្នុងចំណោមវិស័យផ្សេងទៀតនៃសមត្ថកិច្ច ដើម្បីបំរើការងាររហូតដល់សម័យប្រជុំលើកក្រោយនៃរដ្ឋភាគី ដោយមានការយល់ព្រមពីរដ្ឋភាគីភាគច្រើន។ ការយល់ព្រមនេះត្រូវចាត់ទុកជាបានការ ប្រសិនបើរដ្ឋភាគីចំនួនពាក់កណ្តាល ឬច្រើនជាងនេះ មិនបញ្ចេញយោបល់ជំទាស់ក្នុងរយៈពេល៦សប្តាហ៍ បន្ទាប់ពីបានទទួលដំណឹងស្តីពីការស្នើសុំតែងតាំងនេះពីអគ្គលេខាធិការអង្គការសហប្រជាជាតិ។

**មាត្រា ៩**

សមាជិកអនុគណៈកម្មាធិការបង្ការត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតសំរាប់មួយអាណត្តិ ៤ឆ្នាំ។ សមាជិកទាំងនេះមានសិទ្ធិឈរឈ្មោះបោះឆ្នោតបានតែម្តងទៀតប៉ុណ្ណោះ ប្រសិនបើត្រូវបានតែងតាំងជាថ្មី។ អាណត្តិនៃសមាជិកពាក់កណ្តាលដែលជាប់ឆ្នោត នៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ។ បន្ទាប់ពីការបោះឆ្នោតលើកទី១ភ្លាម ឈ្មោះសមាជិកទាំងនោះត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំ ដូចមានចែងក្នុងមាត្រា ៧ កថាខណ្ឌទី១ (ឃ)។

**មាត្រា ១០**

១. អនុគណៈកម្មាធិការបង្ការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីរបស់ខ្លួនសំរាប់អាណត្តិ ២ឆ្នាំ។ មន្ត្រីទាំងនេះ អាចឈរឈ្មោះអោយគេបោះឆ្នោតសាជាថ្មីបាន។

២. អនុគណៈកម្មាធិការបង្ការ ត្រូវបង្កើតវិធាននីតិវិធីរបស់ខ្លួន។ វិធានទាំងនេះត្រូវចែងពីលក្ខខណ្ឌមួយចំនួនដូចជា :

(ក) សមាជិកពាក់កណ្ដាលបូកមួយ (៥០+១) បង្កើតបានជាកូរ៉ុម។

(ខ) សេចក្ដីសំរេចរបស់អនុគណៈកម្មាធិការបង្ការ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកដែលមានវត្តមាន។

(គ) អនុគណៈកម្មាធិការបង្ការ ត្រូវប្រជុំជាសំងាត់ ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំដំបូងរបស់អនុគណៈកម្មាធិការបង្ការ។ បន្ទាប់ពីការប្រជុំដំបូងរបស់ខ្លួន អនុគណៈកម្មាធិការបង្ការ ត្រូវប្រជុំទៅតាមពេលវេលាដែលបានកំណត់នៅក្នុងវិធាននីតិវិធីរបស់ខ្លួន។ អនុគណៈកម្មាធិការបង្ការនិងគណៈកម្មាធិការប្រឆាំងទារុណកម្មត្រូវរៀបចំបើកសម័យប្រជុំរបស់ខ្លួន នៅពេលជាមួយគ្នា យ៉ាងតិចម្ដងក្នុង ១ ឆ្នាំ។

## ផ្នែកទី ៣
## អាណត្តិរបស់អនុគណៈកម្មាធិការបង្ការ

### មាត្រា ១១

១. អនុគណៈកម្មាធិការបង្ការត្រូវ :

(ក) ពិនិត្យកន្លែងឃុំឃាំងទាំងឡាយ ដូចមានចែងក្នុងមាត្រា៤ និងធ្វើអនុសាសន៍ទៅរដ្ឋភាគីអំពីការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

(ខ) ចំពោះយន្តការទប់ស្កាត់ថ្នាក់ជាតិ អនុគណៈកម្មាធិការត្រូវៈ

(១) ផ្ដល់យោបល់ និងជួយរដ្ឋភាគី តាមការចាំបាច់ ក្នុងការបង្កើតយន្តការរបស់ខ្លួន

(២) រក្សាទំនាក់ទំនងផ្ទាល់ ហើយប្រសិនជាចាំបាច់ ជាសំងាត់ជាមួយយន្តការបង្ការថ្នាក់ជាតិ និងផ្ដល់ការបណ្ដុះបណ្ដាល និងជំនួយបច្ចេកទេស ក្នុងគោលបំណងពង្រឹងសមត្ថភាពពួកគេ។

(៣) ណែនាំ និងជួយពួកគេ ក្នុងការវាយតំលៃពីសេចក្ដីត្រូវការ និងមធ្យោបាយចាំបាច់ ដើម្បីពង្រឹងការការពារ ជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

(៤) ធ្វើអនុសាសន៍ និងសេចក្ដីសង្កេតទៅរដ្ឋភាគី ក្នុងគោលដៅពង្រឹងសមត្ថភាព និងអាណត្តិនៃយន្តការបង្ការថ្នាក់ជាតិដើម្បីបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

(គ) សហការ ដើម្បីបង្ការអំពើទារុណកម្មជាទូទៅ ជាមួយស្ថាប័ន និងយន្តការអង្គការសហប្រជាជាតិពាក់ព័ន្ធនានា ព្រមទាំងជាមួយស្ថាប័ន ឬអង្គការអន្តរជាតិ តំបន់ និងជាតិនានា ដែលធ្វើការក្នុងគោលដៅពង្រឹងការការពារជនគ្រប់រូបពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

## មាត្រា ១២

ដើម្បីឱ្យអនុគណៈកម្មាធិការបង្ការអាចបំពេញអាណត្តិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា១១ រដ្ឋភាគីត្រូវអនុវត្តដូចតទៅនេះ :

(ក) ទទួលអនុគណៈកម្មាធិការបង្ការនៅលើទឹកដីរបស់ខ្លួន និងអនុញ្ញាតឱ្យអនុគណៈកម្មាធិការបង្ការចូលពិនិត្យកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ នៃពិធីសារនេះ ។

(ខ) ផ្តល់ព័ត៌មានពាក់ព័ន្ធទាំងឡាយ ដែលអនុគណៈកម្មាធិការបង្ការអាចស្នើសុំ ដើម្បីវាយតំលៃពីសេចក្តីត្រូវការ និងវិធានការនានា ដែលគួរត្រូវបានអនុម័ត ដើម្បីពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(គ) ជំរុញលើកទឹកចិត្ត និងសំរួលដល់ទំនាក់ទំនងរវាងអនុគណៈកម្មាធិការបង្ការ និងយន្តការបង្ការថ្នាក់ជាតិ ។

(ឃ) ពិនិត្យអនុសាសន៍របស់អនុគណៈកម្មាធិការបង្ការ ហើយជួបប្រជុំពិភាក្សាលើអនុសាសន៍នោះអំពីវិធានការពង្រឹងការអនុវត្តមួយចំនួនដែលអាចមាន ។

## មាត្រា ១៣

១. អនុគណៈកម្មាធិការបង្ការត្រូវបង្កើត ជាដំបូងដោយការចាប់ឆ្នោត នូវកម្មវិធីទស្សនកិច្ចជាទៀងទាត់ទៅកាន់រដ្ឋភាគីនានា ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា១១ ។

២. បន្ទាប់ពីមានការពិគ្រោះយោបល់ អនុគណៈកម្មាធិការបង្ការត្រូវជូនដំណឹងទៅរដ្ឋភាគីអំពីកម្មវិធីរបស់ខ្លួន ដើម្បីអោយរដ្ឋនោះអាចធ្វើការរៀបចំចាំបាច់ជាក់ស្តែង ដោយមិនមានការពន្យាពេលដើម្បីសំរួលដល់ដំណើរទស្សនកិច្ចនេះ ។

៣. ទស្សនកិច្ចនេះ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិច ២រូប នៃអនុគណៈកម្មាធិការបង្ការ ។

ប្រសិនជាចាំបាច់ សមាជិកទាំងនេះអាចត្រូវបានអមដំណើរដោយអ្នកជំនាញការទាំងឡាយ ដែលមានបទពិសោធន៍ ផ្នែកវិជ្ជាជីវៈ និងចំណេះដឹងក្នុងវិស័យផ្សេងៗ ដែលគ្របដណ្តប់ដោយពិធីសារនេះ ហើយត្រូវបានជ្រើសរើសចេញពីបញ្ជីឈ្មោះអ្នកជំនាញការដែលបានរៀបចំឡើងដោយផ្អែកលើសំណើររបស់រដ្ឋភាគី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និង មជ្ឈមណ្ឌលអង្គការសហប្រជាជាតិទទួលបន្ទុកការបង្ការឧក្រិដ្ឋកម្ម។ ក្នុងការរៀបចំបញ្ជីឈ្មោះនេះ រដ្ឋភាគីពាក់ព័ន្ធ ត្រូវស្នើឈ្មោះអ្នកជំនាញការជាតិមិនអោយលើសពី៥នាក់ឡើយ ។ រដ្ឋភាគីសាមុីអាចធ្វើការបដិសេធពីការដាក់បញ្ចូលអ្នកជំនាញការឯកទេសណាមួយទៅក្នុងដំណើរទស្សនៈកិច្ចនោះ ហើយក្នុងករណីនេះអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវដាក់សំណើសុំរកអ្នកជំនាញការម្នាក់ផ្សេងទៀត។

៤. ប្រសិនបើអនុគណៈកម្មាធិការបង្ការយល់ថាសមស្រប អនុគណៈកម្មាធិការបង្ការអាចរៀបចំឱ្យមានទស្សនកិច្ចតាមដានរយៈពេលខ្លីមួយបាន បន្ទាប់ពីទស្សនកិច្ចទៀងទាត់នោះ។

## មាត្រា ១៤

១. ដើម្បីឱ្យអនុគណៈកម្មាធិការបង្ការអាចបំពេញអាណត្តិរបស់ខ្លួនបាន រដ្ឋភាគីនៃពិធីសារនេះត្រូវផ្តល់ឱ្យអនុគណៈកម្មាធិការបង្ការ :

(ក) ដោយគ្មានការរិតត្បិត នូវព័តិមានទាំងអស់ដែលទាក់ទងនឹងចំនួនជនដែលត្រូវបានដកហូតសេរីភាពនៅក្នុងកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ ព្រមទាំងចំនួនទីកន្លែង និងទីតាំងរបស់ពួកគេ។

(ខ) ដោយគ្មានការរិតត្បិត នូវសិទ្ធិក្នុងការទទួលបានព័តិមានទាំងអស់ដែលទាក់ទងនឹងប្រព្រឹត្តកម្មលើជនទាំងនោះ ព្រមទាំងលក្ខខណ្ឌនៃការឃុំខ្លួនផង។

(គ) ដោយអនុលោមតាមកថាខ័ណ្ឌទី២ សិទ្ធិចេញចូលដោយគ្មានការរិតត្បិតក្នុងការពិនិត្យកន្លែងឃុំឃាំងទាំងអស់ គ្រឿងឧបករណ៍ និងអាគារនានានៃកន្លែងឃុំឃាំង។

(ឃ) ឱកាសជួបសម្ភាសន៍ជាឯកជន ជាមួយជនដែលត្រូវបានដកហូតសេរីភាព ដោយគ្មានសាក្សីដោយផ្ទាល់ ឬដោយមានអ្នកបកប្រែភាសាម្នាក់ ប្រសិនបើចាំបាច់ ក៏ដូចជា ជាមួយជនផ្សេងទៀត ដែលអនុគណៈកម្មាធិការបង្ការជឿជាក់ថាអាចផ្តល់ព័តិមានពាក់ព័ន្ធបាន។

(ង) សេរីភាពក្នុងការជ្រើសរើសទីកន្លែង ដែលអនុគណៈកម្មាធិការបង្ការចង់ទៅទស្សនកិច្ចនិងជនដែលអនុគណៈកម្មាធិការបង្ការចង់ជួបសម្ភាសន៍។

២. ការជំទាស់ទៅនឹងទស្សនៈកិច្ចក្នុងមន្ទីរឃុំឃាំងណាមួយអាចធ្វើទៅបានតែក្នុងករណីបន្ទាន់

បង្ខំ ដោយមូលហេតុនៃការការពារជាតិ សុវត្ថិភាពសាធារណៈ គ្រោះមហន្តរាយធម្មជាតិ ឬចលាចលធ្ងន់ធ្ងរនៅកន្លែងដែលត្រូវធ្វើទស្សនកិច្ច ដែលរារាំងជាបណ្ដោះអាសន្នដល់ការធ្វើទស្សនកិច្ចនេះ។ អត្ថិភាពនៃការប្រកាសភាពមានអាសន្នបែបនេះ មិនអាចលើកជាសំអាងដោយរដ្ឋភាគីណាមួយ ថាជាហេតុផលដើម្បីជំទាស់ទៅនឹងការធ្វើទស្សនកិច្ចនេះឡើយ។

## មាត្រា ១៥

គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬបណ្ដោយឱ្យមានការដាក់ទណ្ឌកម្មទៅលើបុគ្គល ឬអង្គការណាមួយ ដែលបានទំនាក់ទំនងទៅអនុគណៈកម្មាធិការទប់ស្កាត់ ឬទៅប្រតិភូរបស់ខ្លួននូវព័ត៌មានណាមួយ ទោះជាព័ត៌មាននោះពិត ឬមិនពិតក្ដី ហើយបុគ្គល ឬអង្គការនោះ មិនត្រូវបានទទួលការរើសអើងដោយវិធីនេះឡើយ។

## មាត្រា ១៦

១. អនុគណៈកម្មាធិការបង្ការត្រូវបញ្ជូនអនុសាសន៍ និងសេចក្ដីសង្កេតរបស់ខ្លួនជាសំងាត់ទៅរដ្ឋភាគី ហើយប្រសិនជាមានការពាក់ព័ន្ធ ត្រូវបញ្ជូនទៅយន្តការបង្ការថ្នាក់ជាតិ។

២. អនុគណៈកម្មាធិការទប់ស្កាត់ត្រូវបោះពុម្ពផ្សាយរបាយការណ៍របស់ខ្លួន រួមជាមួយសេចក្ដីផ្ដល់មតិរបស់រដ្ឋភាគីពាក់ព័ន្ធ នៅពេលដែលមានការស្នើសុំដោយរដ្ឋភាគីនោះ។ ប្រសិនបើរដ្ឋភាគីធ្វើការផ្សព្វផ្សាយតែផ្នែកមួយនៃរបាយការណ៍នេះ អនុគណៈកម្មាធិការទប់ស្កាត់ អាចបោះពុម្ពផ្សាយរបាយការណ៍នេះទាំងស្រុង ឬមួយផ្នែកក៏បាន។ ទោះជាយ៉ាងណាក៏ដោយ អនុគណៈកម្មាធិការមិនត្រូវធ្វើការចុះផ្សាយនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គល ដោយគ្មានការយល់ព្រមពីសាមីជននោះឡើយ។

៣. អនុគណៈកម្មាធិការបង្ការត្រូវបង្ហាញរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈ ស្ដីពីសកម្មភាពរបស់ខ្លួនទៅគណៈកម្មាធិការប្រឆាំងទារុណកម្ម។

៤.ប្រសិនបើរដ្ឋភាគីបដិសេធមិនព្រមសហការជាមួយអនុគណៈកម្មាធិការទប់ស្កាត់ ស្របតាមមាត្រា១២ និងមាត្រា១៤ ឬមិនព្រមចាត់វិធានការ ដើម្បីកែលំអស្ថានភាព តាមស្មារតីនៃអនុសាសន៍របស់អនុគណៈកម្មាធិការទប់ស្កាត់ គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម អាចផ្អែកតាមការស្នើសុំរបស់គណៈកម្មាធិការទប់ស្កាត់ សំរេចដោយសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន បន្ទាប់ពីរដ្ឋភាគីមានឱកាសបញ្ចេញពីការយល់ឃើញរបស់ខ្លួន ធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈអំពីបញ្ហានោះឬបោះពុម្ពផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការទប់ស្កាត់។

# ផ្នែកទី ៤
# យន្តការបង្ការថ្នាក់ជាតិ

## មាត្រា ១៧

រដ្ឋភាគីនីមួយៗត្រូវរក្សា ចាត់តាំង ឬបង្កើតយន្តការបង្ការឯករាជថ្នាក់ជាតិមួយ ឬច្រើន ដើម្បីបង្ការការធ្វើទារុណកម្មនៅថ្នាក់ជាតិ យ៉ាងយូរបំផុតរយៈពេល ១ឆ្នាំ បន្ទាប់ពីថ្ងៃចូលជាធរមាននៃពិធីសារនេះ ឬនៃការឱ្យសច្ចាប័ន ឬនៃការចូលជាសមាជិករបស់ខ្លួន។ យន្តការដែលបានបង្កើតដោយអង្គភាពវិមជ្ឈការនានាអាចត្រូវបានចាត់តាំងជាយន្តការបង្ការថ្នាក់ជាតិ ដើម្បីគោលបំណងនៃពិធីសារនេះ ប្រសិនបើយន្តការទាំងនេះស្របទៅនឹងបទបញ្ញត្តិនៃពិធីសារនេះ។

## មាត្រា ១៨

១. រដ្ឋភាគីត្រូវធានាការពារឯករាជ្យភាពមុខងាររបស់យន្តការបង្ការថ្នាក់ជាតិ ក៏ដូចជាឯករាជ្យភាពនៃបុគ្គលិករបស់ខ្លួន។

២. រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា អ្នកជំនាញការនៃយន្តការបង្ការថ្នាក់ជាតិមានចំណេះដឹងវិជ្ជាជីវៈ និងសមត្ថភាពដូចដែលបានទាមទារ។ រដ្ឋភាគីត្រូវខិតខំរក្សាឱ្យបានតុល្យភាពខាងយេនឌ័រ និងភាពជាតំណាងគ្រប់គ្រាន់នៃក្រុមជាតិពន្ធុ និងក្រុមជនជាតិភាគតិចនៅក្នុងប្រទេស។

៣. រដ្ឋភាគីត្រូវផ្តល់ធនធានដែលចាំបាច់សំរាប់ការប្រព្រឹត្តទៅនៃយន្តការបង្ការថ្នាក់ជាតិ។

៤. នៅពេលបង្កើតយន្តការបង្ការថ្នាក់ជាតិ រដ្ឋភាគីត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវ ចំពោះគោលការណ៍ទាក់ទងនឹងឋានៈ និងការប្រព្រឹត្តទៅនៃស្ថាប័នជាតិទទួលបន្ទុកការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស។

## មាត្រា ១៩

យ៉ាងហោចណាស់ យន្តការបង្ការថ្នាក់ជាតិ ត្រូវមានអំណាចដូចខាងក្រោម :

(ក) ពិនិត្យយ៉ាងទៀងទាត់ អំពីការប្រព្រឹត្តទៅលើជនដែលត្រូវបានដកហូតសេរីភាព នៅក្នុងទីកន្លែងទាំងឡាយដូចមានចែងក្នុងមាត្រា៤ ប្រសិនជាចាំបាច់ ក្នុងគោលដៅពង្រឹងការការពារដល់ពួកគេពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

(ខ) ផ្ដល់អនុសាសន៍ដល់អាជ្ញាធរពាក់ព័ន្ធ ក្នុងគោលបំណងកែលំអការប្រព្រឹត្ត និងលក្ខខណ្ឌនៃជនដែលត្រូវបានដកហូតសេរីភាព និងដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដោយពិនិត្យទៅលើលិខិតបទដ្ឋានពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ។

(គ) លើកសំណើ និងសេចក្ដីសង្កេតពាក់ព័ន្ធនឹងច្បាប់ដែលកំពុងមានជាធរមាន និងសេចក្ដីព្រាងច្បាប់នានា។

## មាត្រា ២០

ដើម្បីឱ្យយន្តការបង្ការថ្នាក់ជាតិ អាចបំពេញអាណត្តិរបស់ខ្លួនបាន រដ្ឋភាគីនៃពិធីសារនេះ ត្រូវអនុញ្ញាតឱ្យយន្តការនេះនូវ :

(ក) សិទ្ធិទទួលបានរាល់ព័ត៌មានពាក់ព័ន្ធនឹងចំនួនជនដែលត្រូវបានដកហូតសេរីភាព នៅក្នុងកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ ក៏ដូចជាចំនួនកន្លែង និងទីតាំងរបស់ពួកគេ។

(ខ) សិទ្ធិទទួលបានរាល់ព័ត៌មាន ដែលនិយាយពីការប្រព្រឹត្តទៅលើជនទាំងនេះ ក៏ដូចជាស្ថានភាពនៃការឃុំខ្លួនរបស់ពួកគេផងដែរ។

(គ) សិទ្ធិចេញចូលពិនិត្យរាល់ទីកន្លែងឃុំឃាំង រចនាសម្ពន្ធនានានៃទីកន្លែងឃុំឃាំង និងគ្រឿងឧបករណ៍។

(ឃ) ឱកាសជួបសម្ភាសន៍ជាឯកជនជាមួយជនដែលត្រូវបានដកហូតសេរីភាព ដោយគ្មានសាក្សីទោះជាដោយផ្ទាល់ឬដោយមានអ្នកបកប្រែភាសាម្នាក់ ប្រសិនបើចាំបាច់ ព្រមទាំងជាមួយជនផ្សេងទៀតដែលយន្តការបង្ការថ្នាក់ជាតិយល់ថាអាចផ្ដល់ព័ត៌មានពាក់ព័ន្ធបាន។

(ង) សេរីភាពក្នុងការជ្រើសរើសទីកន្លែងដែលខ្លួនចង់ទៅទស្សនកិច្ច និងជនដែលខ្លួនចង់ជួបសម្ភាសន៍។

(ច) សិទ្ធិមានទំនាក់ទំនងជាមួយអនុគណៈកម្មាធិការបង្ការ ដើម្បីផ្ដល់ព័ត៌មាន និងជួបប្រជុំជាមួយអនុគណៈកម្មាធិការបង្ការនេះ។

## មាត្រា ២១

១. គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬបណ្ដោយឱ្យមានការដាក់ទណ្ឌកម្មទៅ

លើបុគ្គល ឬអង្គការណាមួយ ពីការបានធ្វើទំនាក់ទំនងផ្តល់ព័ត៌មានដល់យន្តការទប់ស្កាត់ថ្នាក់ជាតិ ទោះជាព័ត៌មាននោះពិត ឬមិនពិតក្តី ហើយបុគ្គល ឬអង្គការទាំងនេះ មិនត្រូវទទួលរងការរើសអើងតាមវិធីណាមួយឡើយ ។

២. ព័ត៌មានសំងាត់ដែលប្រមូលបានដោយយន្តការបង្ការថ្នាក់ជាតិ ត្រូវបានផ្តល់បុព្វសិទ្ធិ។ គ្មានព័ត៌មានផ្ទាល់ខ្លួនត្រូវបានចុះផ្សាយដោយគ្មានការយល់ព្រមពីសាម៉ីជននោះឡើយ ។

**មាត្រា ២២**

អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីពាក់ព័ន្ធ ត្រូវពិនិត្យមើលអនុសាសន៍របស់យន្តការបង្ការថ្នាក់ជាតិ ហើយត្រូវធ្វើការពិភាក្សាជាមួយយន្តការនេះ អំពីវិធានការអនុវត្តដែលអាចមាន ។

**មាត្រា ២៣**

រដ្ឋភាគីនៃពិធីសារនេះ មានភារកិច្ចបោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការបង្ការថ្នាក់ជាតិ ។

## ផ្នែកទី ៥

## សេចក្តីប្រកាស

**មាត្រា ២៤**

១. នៅពេលផ្តល់សច្ចាប័ន រដ្ឋភាគីអាចប្រកាសលើកពេលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របតាមផ្នែកទី៣ ឬផ្នែកទី៤ នៃពិធីសារនេះបាន ។

២. ការពន្យាពេលនេះ ត្រូវមានសុពលភាពរយៈពេលអតិបរមា ៣ឆ្នាំ។ បន្ទាប់ពីរដ្ឋភាគីបានធ្វើសេចក្តីថ្លែងការណ៍យ៉ាងត្រឹមត្រូវ និងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអនុគណៈកម្មាធិការបង្ការគណៈកម្មាធិការប្រឆាំងទារុណកម្ម អាចពន្យាពេលដែលបានកំណត់នេះរយៈពេល ២ឆ្នាំបន្ថែមទៀត ។

## ផ្នែកទី ៦

## បទប្បញ្ញត្តិហិរញ្ញវត្ថុ

**មាត្រា ២៥**

១.ការចំណាយរបស់អនុគណៈកម្មាធិការបង្ការក្នុងការអនុវត្តន៍ពិធីសារនេះគឺជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិកចាំបាច់ និងអាគារសំរាប់ឱ្យអនុគណៈកម្មាធិការបង្ការបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ស្របតាមពិធីសារនេះ ។

## មាត្រា ២៦

១. មូលនីធិពិសេសមួយ ត្រូវបានបង្កើតឡើង ស្របតាមនីតិវិធីពាក់ព័ន្ធរបស់មហាសន្និបាត ដែលមូលនីធិនេះត្រូវចាត់ចែងស្របតាមវិធាន និងបទបញ្ញត្តិហិរញ្ញវត្ថុរបស់អង្គការសហប្រជាជាតិ ដើម្បីជួយជាហិរញ្ញវត្ថុដល់ការអនុវត្តន៏អនុសាសន៍ទាំងឡាយ ដែលបានធ្វើឡើងដោយអនុគណៈកម្មាធិការបង្ការចំពោះរដ្ឋភាគីមួយ បន្ទាប់ពីការធ្វើទស្សនកិច្ចទៅកាន់រដ្ឋភាគីនោះ ព្រមទាំង ជួយក្នុងកម្មវិធីអប់រំរបស់យន្តការបង្ការថ្នាក់ជាតិ ។

២. មូលនីធិពិសេសនេះ អាចត្រូវផ្តល់តាមរយៈវិភាគទានស្ម័គ្រចិត្តដោយរដ្ឋាភិបាលនានា អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គភាពសាធារណៈ ឬឯកជនដទៃទៀត ។

## ផ្នែកទី ៧

## អវសានប្បញ្ញត្តិ

## មាត្រា ២៧

១. ពិធីសារនេះ បើកឱ្យចុះហត្ថលេខា ដោយរដ្ឋភាគីដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយរដ្ឋណាក៏ដោយដែលបានឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។លិខិតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ បើកឱ្យចូលជាសមាជិកដោយរដ្ឋណាក៏ដោយដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

៤. ការចូលជាសមាជិក ត្រូវមានជាធរមានបញ្ញត្តិ គិតចាប់ពីការតំកល់លិខិតុបករណ៍នៃការចូលជាសមាជិកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដែលបានចុះហត្ថលេខាលើពិធីសារនេះ ឬដែលបានចូលជាសមាជិកនៃពិធីសារនេះ អំពីលិខិតុបករណ៍នីមួយៗនៃការឱ្យសច្ចាប័នឬការចូលជាសមាជិក ។

**មាត្រា ២៨**

១. ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ទី២០នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. ចំពោះរដ្ឋនីមួយៗដែលនឹងផ្តល់សច្ចាប័ន ឬនឹងចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការតំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ពិធីសារនេះនឹងចូលជាធរមានសំរាប់រដ្ឋនោះនៅ៣០ថ្ងៃ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់ខ្លួន។

**មាត្រា ២៩**

បទបញ្ញត្តិនៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិតព្រំដែន ឬការលើកលែងឡើយ។

**មាត្រា ៣០**

មិនអនុញ្ញាតឱ្យដាក់ខលក្ខខណ្ឌណាមួយ ចំពោះពិធីសារនេះឡើយ។

**មាត្រា ៣១**

បទបញ្ញត្តិនៃពិធីសារនេះ មិនបានធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីក្រោមអនុសញ្ញាតំបន់ដែលបង្កើតប្រព័ន្ធពិនិត្យកន្លែងឃុំឃាំងនានានោះទេ។ អនុគណៈកម្មាធិការបង្ការ និងស្ថាប័នដទៃទៀតដែលបានបង្កើតឡើងក្រោមអនុសញ្ញាតំបន់ទាំងនោះ ត្រូវបានជំរុញលើកទឹកចិត្តឱ្យពិគ្រោះយោបល់ និងសហការក្នុងគោលបំណងជៀសវាងការងារត្រួតគ្នា និង ដើម្បីលើកស្ទួយដល់គោលដៅនៃពិធីសារនេះអោយមានប្រសិទ្ធភាព។

**មាត្រា ៣២**

បទបញ្ញត្តិនៃពិធីសារនេះ មិនបានធ្វើអោយប៉ះពាល់ដល់កាតព្វកិច្ចនៃរដ្ឋភាគី ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវទាំង៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមនានានៃអនុសញ្ញាទាំងនោះ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ ទេ ឬឱកាសដែលមានចំពោះរដ្ឋភាគីណាមួយ ដើម្បីអនុញ្ញាតឱ្យគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ចូលទៅពិនិត្យកន្លែងឃុំឃាំង ក្នុងស្ថានភាពដែលមិនស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិនោះក៏ទេដែរ។

## មាត្រា ៣៣

១. រដ្ឋភាគីណាក៏ដោយ ក៏អាចដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេលវេលាដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវជូនដំណឹងនេះទៅរដ្ឋភាគីដទៃទៀតនៃពិធីសារ និងអនុសញ្ញានេះ។ ការដកខ្លួននឹងចូលជាធរមាន ១ឆ្នាំ ក្រោយពីកាលបរិច្ឆេទនៃការទទួលបានលិខិតជូនដំណឹងនេះពីលោកអគ្គលេខាធិការ។

២. ការដកខ្លួននេះ នឹងមិនលើកលែងឱ្យរដ្ឋភាគីរួចកាតព្វកិច្ចរបស់ខ្លួនពីពិធិសារនេះទេ ចំពោះអំពើ ឬស្ថានការណ៍ណាមួយដែលកើតមុនកាលបរិច្ឆេទនៃការសុំដកខ្លួនបានចូលជាធរមាន ឬសកម្មភាពទាំងឡាយដែលអនុគណៈកម្មាធិការបង្ការបានសំរេច ឬអាចសំរេចអនុម័តយកមកចាត់ការចំពោះរដ្ឋភាគីពាក់ព័ន្ធ ហើយការសុំដកខ្លួននេះ ក៏មិនធ្វើអោយខូចខាតដល់ការពិចារណាលើបញ្ហាកំពុងបន្ត ដែលស្ថិតក្រោមការពិនិត្យរបស់អនុគណៈកម្មាធិការបង្ការមុនកាលបរិច្ឆេទនៃការសុំដកខ្លួនបានចូលជាធរមាននោះឡើយ។

៣. បន្ទាប់ពីកាលបរិច្ឆេទនៃការសុំដកខ្លួនរបស់រដ្ឋភាគីចូលជាធរមាន អនុគណៈកម្មាធិការបង្ការមិនត្រូវចាប់ផ្តើមពិនិត្យបញ្ហាថ្មីណាមួយទាក់ទងនឹងរដ្ឋនោះទៀតទេ។

## មាត្រា ៣៤

១. រដ្ឋភាគីណាមួយនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើធ្វើវិសោធកម្មនេះ ទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ប្រាប់មកលោកវិញថា តើខ្លួនយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគី ដើម្បីពិនិត្យ និងបោះឆ្នោតគាំទ្រសេចក្តីស្នើសុំនោះឬទេ។ ក្នុងរយៈពេល៤ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនព័ត៌មានទៅរដ្ឋភាគី បើមានសម្លេង១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានកិច្ចប្រជុំ លោកត្រូវកោះប្រជុំសន្និសិទ្ធនេះ ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ រាល់វិសោធនកម្មត្រូវអនុម័តដោយសម្លេងភាគច្រើន ២ភាគ៣ នៃរដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោតនៅឯកិច្ចប្រជុំ ហើយអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនវិសោធនកម្មនេះទៅរដ្ឋភាគីទាំងអស់ ដើម្បីសុំការទទួលយក។

២. វិសោធនកម្ម ដែលបានអនុម័តស្របតាមបទបញ្ញត្តិកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលដែលវិសោធនកម្មនេះ ត្រូវបានទទួលយកដោយសម្លេងភាគច្រើនចំនួន ២ភាគ៣ នៃរដ្ឋ

សមាជិកពិធីសារនេះ ដោយអនុលោមតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

៣. នៅពេលវិសោធនកម្មចូលជាធរមាន រដ្ឋភាគីដែលព្រមទទួលយកវិសោធនកម្មនេះ ត្រូវជាប់កាតព្វកិច្ចក្រោមវិសោធនកម្មនេះ ចំពោះរដ្ឋភាគីដទៃទៀត នៅតែជាប់កាតព្វកិច្ចក្រោមបទបញ្ញត្តិ នៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានយល់ព្រមទទួលយក។

## មាត្រា ៣៥

សមាជិកអនុគណៈកម្មាធិការបង្ការ និងសមាជិកយន្តការបង្ការថ្នាក់ជាតិត្រូវទទួលបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយ តាមការចាំបាច់ សំរាប់អនុវត្តមុខងាររបស់ខ្លួនប្រកបដោយឯករាជ្យភាព។ សមាជិកគណៈកម្មាធិការបង្ការត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយ ដូចមានចែងក្នុងផ្នែកទី២២ នៃអនុសញ្ញាស្តីពី បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៤៦ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃផ្នែកទី២៣ នៃអនុសញ្ញានោះ។

## មាត្រា ៣៦

នៅពេលធ្វើទស្សនកិច្ចនៅរដ្ឋភាគីមួយ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិនិងគោលបំណងនៃពិធីសារនេះ ជាមួយបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលមាន សមាជិកអនុគណៈកម្មាធិការបង្ការត្រូវ ៖

(ក) គោរពច្បាប់ និងបទបញ្ជារបស់រដ្ឋម្ចាស់ផ្ទះ។

(ខ) ប្រាសចាកពី អំពើ ឬសកម្មភាពណាមួយ ដែលមិនស្របទៅនឹងចរិតអន្តរជាតិ និង ភាពឥតលំអៀងនៃភារកិច្ចរបស់ខ្លួនឡើយ។

## មាត្រា ៣៧

១. ពិធីសារនេះ ដែលតាក់តែងឡើងជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃគតិយុត្តិស្មើគ្នា ហើយត្រូវតំកល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ពីការថតចម្លងតាមច្បាប់ដើមផងទៅរដ្ឋភាគីទាំងអស់។

--------//--------